ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរកឃើញផលិតផលបំប៉នសុខភាព និងគ្រឿងសម្អាងមានលួចដាក់សារធាតុសកម្ម ឱសថសម័យ និងសារធាតុគីមីប្រើប្រាស់លើសកម្រិតស្តង់ដា

ក្រសួងសុខាភិបាល សូមជម្រាបជូនដល់សាធារណជនទាំងអស់មេត្តាជ្រាបថា នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៥ ស្នងការដ្ឋាននគរបាលខេត្តកណ្តាល បានសហការជាមួយក្រុមការងារមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តកណ្តាល និងអាជ្ញាធរពាក់ព័ន្ធ បានចុះអនុវត្តច្បាប់នៅគេហដ្ឋានរបស់លោកស្រី ឆេង ស្រីរ័ត្ន ម្ចាស់គ្រឹះស្ថានអាហារ័ណ នីហារ័ណ ផលិតផលគ្រឿងសម្អាង **ឡាហ្វ រីយ៉ា** ឯ.ក ដោយបានស្រង់យកសំណាកផលិតផលបំប៉នសុខភាព ចំនួន ២មុខ និងគ្រឿងសម្អាង ចំនួន ១២មុខ មកវិភាគគុណភាព នៅមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ដែលក្នុងចំណោមនោះ មានផលិតផលបំប៉នសុខភាពចំនួន ២មុខ និងផលិតផលគ្រឿងសម្អាងចំនួន ៣មុខ ដែលគ្មានលេខបញ្ជិកា ឬលេខប្រវេទន៍ ពីក្រសួងសុខាភិបាល។

យោងតាមលទ្ធផលវិភាគគុណភាពរបស់មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាលបានបង្ហាញថា៖

- ផលិតផលបំប៉នសុខភាពឈ្មោះ LOVE RIYA ថ្នាំលេបបាត់ជាំ ដែលគ្មានលេខបញ្ជិកាពីក្រសួងសុខាភិបាល មានលួចដាក់សារធាតុសកម្មឱសថ Tranexamic Acid។ សារធាតុឱសថ Tranexamic Acid ត្រូវបានគេប្រើប្រាស់សម្រាប់ការឃាត់ឈាមក្រោមការត្រួតពិនិត្យរបស់វេជ្ជបណ្ឌិត ឬគ្រូពេទ្យ។
- គ្រឿងសម្អាងចំនួន ២មុខ គ្មានលេខប្រវេទន៍ ពីក្រសួងសុខាភិបាលឈ្មោះ Loveriya Double White Body Lotion និង Loveriya ម្សៅលាបមុខព្យាបាលមុនសាច់ មុនអង្កាម មុនខ្ទុះ មុនផ្កាស្បូន ស្នាមជាំ មានផ្ទុកសារធាតុគីមី Salicylic Acid និងបារត (Mercury) លើសកម្រិតស្តង់ដា ដែលបានកំណត់ក្នុងមគ្គទេសក៍គ្រឿងសម្អាងអាស៊ាន។ សារធាតុគីមី Salicylic Acid លើសកម្រិតស្តង់ដាបង្កផលប៉ះពាល់ដល់សុខភាព ដូចជាស្បែកស្ងួត របកស្បែក និងប្រតិកម្មអាល់ឡែស៊ីស្បែក។ សារធាតុគីមី បារត (Mercury) លើសកម្រិតស្តង់ដាបង្កផលប៉ះពាល់ដល់សុខភាព ដូចជាខ្សោយតម្រងនោម មហារីកស្បែក និងប៉ះពាល់ប្រព័ន្ធប្រសាទ។

ដើម្បីចៀសវាងការប្រើប្រាស់ផលិតផល ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ឬសារធាតុលើសកម្រិតស្តង់ដាខាងលើ ក្រសួងសុខាភិបាល សូមជម្រាបជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវបញ្ឈប់ការទិញ និងប្រើប្រាស់ផលិតផលទាំង ៣មុខនេះជាបន្ទាន់។ ទន្ទឹមនេះដែរ សូម សាធារណជនទាំងអស់ត្រូវបញ្ឈប់ការប្រើប្រាស់ផលិតផលបំប៉នសុខភាពគ្មានលេខបញ្ជិកា និងគ្រឿងសម្អាងគ្មានលេខប្រវេទន៍ពីក្រសួងសុខាភិបាល ដើម្បីចៀសវាងការខាតបង់ប្រាក់ និងប៉ះពាល់ដល់សុខភាព ឬឈានដល់បាត់បង់អាយុជីវិត ដោយផលិតផលទាំងនេះ ពុំធានាបាននូវគុណភាព សុវត្ថិភាព ស្របតាមបទដ្ឋានបច្ចេកទេសឡើយ។



អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

ក្រសួងសុខាភិបាល សូមជម្រាបជូនថា រាល់ការចរាចរផលិតផលបំប៉នសុខភាព និងគ្រឿងសម្អាងគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវមានលេខបញ្ជិកា និងលេខប្រវេទន៍ទទួលស្គាល់ពីក្រសួងសុខាភិបាល ដូចមានគំរូភ្ជាប់មកជាមួយ។

ក្រសួងសុខាភិបាល តម្រូវឱ្យបុគ្គលដែលបានចែកចាយ ឬលក់ផលិតផលទាំង៣ខាងលើ ឬផលិតផលបំប៉នសុខភាពគ្មានលេខបញ្ជិកា ឬគ្រឿងសម្អាងគ្មានលេខប្រវេទន៍ផ្សេងទៀត រួមទាំងជនពាក់ព័ន្ធដទៃទៀត ត្រូវបញ្ឈប់ការនាំចូល ចែកចាយ ឬលក់ផលិតផលទាំងនេះជាបន្ទាន់។ ក្រសួងសុខាភិបាលនឹងមានវិធានការតឹងរ៉ឹងទៅតាមផ្លូវច្បាប់ចំពោះជនណាដែលបន្តចែកចាយ ឬលក់ផលិតផលបំប៉នសុខភាពគ្មានលេខបញ្ជិកាខាងលើ ឬផលិតផលគ្មានលេខបញ្ជិកាផ្សេងទៀត ទៅតាមច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងឱសថជាធរមាន។

ក្រសួងសុខាភិបាល សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋ អាជីវករ នឹងចូលរួមសហការអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃពុធ ១១កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៥

# គំរូលតាបត្របញ្ជិកាផលិតផលបំប៉នសុខភាព

| | | |
|---|---|---|
| ឈ្មោះគ្រឹះស្ថានអាហរ័ណ នីហរ័ណ | → | XXX Pharma CO., LTD. |
| លេខបញ្ជិកា | → | CAM N0001IH-20 |

| | | |
|---|---|---|
| ឈ្មោះគ្រឹះស្ថានអាហរ័ណ នីហរ័ណ | → | YYY Pharma CO., LTD. |
| លេខបញ្ជិកា | → | CAM $R_1$0002IH-17 |

| | | |
|---|---|---|
| ឈ្មោះគ្រឹះស្ថានអាហរ័ណ នីហរ័ណ | → | YYY Pharma CO., LTD. |
| លេខបញ្ជិកា | → | CAM $R_2$0003IH-14 |

# គំរូលតាបត្រប្រវេទន៍គ្រឿងសម្អាង

| | | |
|---|---|---|
| ឈ្មោះគ្រឹះស្ថានអាហរ័ណ នីហរ័ណ | → | XXX Company CO., LTD. |
| លេខប្រវេទន៍ | → | CAM 00001CN-23 |

| | | |
|---|---|---|
| ឈ្មោះគ្រឹះស្ថានអាហរ័ណ នីហរ័ណ | → | YYY Company CO., LTD. |
| លេខប្រវេទន៍ | → | CAM 00002CN-24 |

| | | |
|---|---|---|
| ឈ្មោះគ្រឹះស្ថានអាហរ័ណ នីហរ័ណ | → | YYY Company CO., LTD. |
| លេខប្រវេទន៍ | → | CAM N00003CN-25 |

# ផលិតផលបំប៉នសុខភាព LOVE RIYA ថ្នាំលេបបាត់ជាំ មានលួចដាក់សារធាតុសកម្មឱសថ Tranexamic Acid



## គ្រឿងសម្អាង LOVERIYA DOUBLE WHITE BODY LOTION និង LOVERIYA ម្សៅលាបមុខព្យាបាលមុនសាច់ មុនអង្គាម មុនខ្ទុះ មុនផ្កាស្បូន ស្នាមជាំ មានផ្ទុកសារធាតុគីមី Salicylic Acid និងសារធាតុគីមីបារត (Mercury) លើសកម្រិតស្តង់ដា

